ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ២៩ សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់ការធ្វើអាជីវកម្មខ្សាច់

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១** : ដើម្បីការពារបាននូវលំនឹងបរិស្ថានធម្មជាតិ ទាំងដែនទឹកសាប ទាំងដែនសមុទ្រ ការធ្វើអាជីវកម្មខ្សាច់គ្រប់ប្រភេទក្នុងក្របខ័ណ្ឌទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម :

១- ចំពោះការធ្វើអាជីវកម្មខ្សាច់ទឹកសាប :

ខ្សាច់ទឹកសាបដែលមាននៅក្នុងទន្លេ ស្ទឹង ព្រែក អូរ... អាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបានក្នុងករណី:

-តែការធ្វើអាជីវកម្មនេះ គឺដើម្បីបម្រើដល់តម្រូវការប្រើប្រាស់ក្នុងស្រុកតែប៉ុណ្ណោះ

-អាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបានតែនៅកន្លែងណា ដែលបច្ចេកទេសពិនិត្យទៅឃើញថាមានខ្សាច់ដុះកកស្ទះជាហេតុបណ្តាលឱ្យប៉ះពាល់ដល់ផ្លូវទឹកតែប៉ុណ្ណោះ

-បញ្ឈប់ការនាំខ្សាច់ចេញទៅក្រៅប្រទេស។

២- ចំពោះការធ្វើអាជីវកម្មខ្សាច់សមុទ្រ :

-មិនអនុញ្ញាតអោយធ្វើអាជីវកម្មលើធនធានខ្សាច់សមុទ្រ ទោះជាទីតាំងនោះស្ថិតនៅឆ្ងាយពីឆ្នេរ ឬពីកោះក៏ដោយ។

-អាចអនុញ្ញាតបានចំពោះតែកន្លែងណាដែលមានខ្សាច់ដុះគោករាក់ និងអាចបំពេញវិញបានជាលក្ខណៈធម្មជាតិ តែត្រូវបំពេញល័ក្ខខ័ណ្ឌបច្ចេកទេសជាមុន។

**មាត្រា ២** : គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ត្រូវធ្វើការត្រួតពិនិត្យឡើងវិញជាបន្ទាន់ ទៅតាមការកំណត់នៃការធ្វើអាជីវកម្មដូចមានចែងក្នុងប្រការ ១ ដើម្បីធ្វើរបាយការណ៍ជូន សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីពិនិត្យ និង សំរេច។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤

"ដើម្បីជូនជ្រាប "

- ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ : លោក ឈឹម ទីណា